**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ: ១១ អយក.២០១៥**

# សេចក្ដីណែនាំ
# ស្ដីពី
# ការជំរុញដំណើរការសួនសាលារៀនសម្រាប់ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភនៅកម្ពុជា នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ

យោងរបាយការណ៍កិច្ចប្រជុំពិភាក្សាថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងលិខិតលេខ ៣៩អយក.សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការគ្រប់គ្រងការងារអប់រំបច្ចេកទេសនៅតាមរាជធានី ខេត្ត។ កន្លងមកក្រសួងសង្កេតឃើញ មានគ្រឹះស្ថានសិក្សាមួយចំនួនមិនទាន់អនុវត្តបានល្អប្រសើរនៅឡើយ ជាពិសេសបញ្ហាសួនបន្លែ បង្គន់អនាម័យ និងទឹកស្អាតក្នុងបរិវេណគ្រឹះស្ថានសិក្សា។

ដើម្បីពង្រឹងការអនុវត្តផ្នែកអប់រំបំណិនជីវិត ដែលបានផ្សព្វផ្សាយកន្លងមកឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំអនុវត្តស្ដីពីការជំរុញដំណើរការសួនបន្លែ បង្គន់អនាម័យ និងទឹកស្អាត នៅតាមសាលារៀន (បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ) សម្រាប់ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភនៅកម្ពុជា នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ដូចខាងក្រោម ៖

១-ត្រូវជំរុញដំណើរការសួនបន្លែ បង្គន់អនាម័យ និងទឹកស្អាតរបស់គ្រឹះស្ថានសិក្សា ក្នុងគោលបំណងដើម្បីធានាឱ្យសិស្សានុសិស្សមានសុខភាពល្អ និងមានអាហារូបត្ថម្ភគ្រប់គ្រាន់។

២-ត្រូវត្រៀមចាត់តាំងគ្រូបង្គោល ដើម្បីទទួលការបណ្ដុះបណ្ដាលពីអង្គការស្បៀងអាហារ និងកសិកម្ម(FAO) និងកម្មវិធីស្បៀងអាហារពិភពលោក(WFP) អំពីជំនាញកសិកម្ម និងអនាម័យ។

៣-ត្រូវធ្វើទំនាក់ទំនងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានា ដើម្បីសហការអនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាព។

៤-រៀបចំតារាងសម្រង់ស្ថិតិសួនបន្លែ បង្គន់អនាម័យ និងទឹកស្អាត តាមគំរូជូនភ្ជាប់ រួចបញ្ជូនមកក្រសួង(នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងនាយកដ្ឋានបឋមសិក្សា) ឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០១៥ ដើម្បីក្រសួងមានលទ្ធភាពសិក្សា វិភាគ និងស្វែងរកការគាំទ្រការអនុវត្តនេះ។

ក្រសួងសង្ឃឹម និងជឿជាក់លើស្មារតីទទួលខុសត្រូវខ្ពស់របស់លោក លោកស្រីប្រធានក្នុងការយកចិត្តទុកដាក់អនុវត្តសេចក្ដីណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

កន្លែងទទួល ៖
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
-ក្រសួងកសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន សុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលារាជធានី ខេត្ត
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
-ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ
"ដើម្បីសហការអនុវត្ត"
-គ្រប់គ្រឹះស្ថានសិក្សា "ដើម្បីអនុវត្ត"
-កាលប្បវត្តិ ឯកសារ នា.មចទ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

(គំរូ)

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ..........**

**តារាងសម្រង់ស្ថិតិសួនបន្លែ បង្គន់អនាម័យ និងទឹកស្អាត ក្នុងឆ្នាំសិក្សា២០១៤-ឆ្នាំ២០១៥**

| ល.រ | គ្រឹះស្ថានសិក្សា | សួនបន្លែ | | | | | បង្គន់អនាម័យ | | | ទឹកស្អាត | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មាន | គ្មាន | ផ្លែក្រឡា | ដំណើរការ | មិនដំណើរការ | សរុប | ប្រើប្រាស់បាន | ខូច | សរុប | ប្រើប្រាស់បាន | ខូច |
| ១ | បឋមសិក្សា... | | | | | | | | | | | |
| ២ | បឋមសិក្សា.. | | | | | | | | | | | |
| ... | | | | | | | | | | | | |
| ... | | | | | | | | | | | | |
| .... | | | | | | | | | | | | |
| .. | | | | | | | | | | | | |
| .. | | | | | | | | | | | | |
| ... | | | | | | | | | | | | |

.................... ថ្ងៃទី ខែ ឆ្នាំ២០១៥

**អ្នកស្រង់**

**បានពិនិត្យត្រឹមត្រូវ**

..................... ថ្ងៃទី ខែ ឆ្នាំ២០១៥

**ប្រធានការិយាល័យបឋមសិក្សា**

**បានឃើញ និងឯកភាព**

............. ថ្ងៃទី ខែ ឆ្នាំ២០១៥

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត.......**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

(គំរូ)

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ...........**

**តារាងសម្រង់ស្ថិតិសួនបន្លែ បង្គន់អនាម័យ និងទឹកស្អាត ក្នុងឆ្នាំសិក្សា២០១៤-ឆ្នាំ២០១៥**

| ល.រ | គ្រឹះស្ថានសិក្សា | សួនបន្លែ | | | | | បង្គន់អនាម័យ | | | ទឹកស្អាត | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មាន | គ្មាន | ផ្ទៃក្រឡា | ដំណើរការ | មិនដំណើរការ | សរុប | ប្រើប្រាស់បាន | ខូច | សរុប | ប្រើប្រាស់បាន | ខូច |
| ១ | អនុវិទ្យាល័យ........ | | | | | | | | | | | |
| ២ | អនុវិទ្យាល័យ....... | | | | | | | | | | | |
| ... | | | | | | | | | | | | |
| ... | | | | | | | | | | | | |
| .... | វិទ្យាល័យ........... | | | | | | | | | | | |
| .. | វិទ្យាល័យ........... | | | | | | | | | | | |
| .. | | | | | | | | | | | | |
| ... | | | | | | | | | | | | |

.................... ថ្ងៃទី ខែ ឆ្នាំ២០១៥

**អ្នកស្រង់**

**បានពិនិត្យត្រឹមត្រូវ**

..................... ថ្ងៃទី ខែ ឆ្នាំ២០១៥

**ប្រធានការិយាល័យមធ្យមសិក្សា**

**បានឃើញ និងឯកភាព**

............ ថ្ងៃទី ខែ ឆ្នាំ២០១៥

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត.......**